## អភិបូជាប្រសិទ្ធីពរលើគ្លីនិកភូមិសុ
## ធ្វើនៅគ្លីនិកភូមិសុ ព្រៃស
## ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
## “បើកទំព័រថ្មីនៃការសហការ”

**អត្ថបទទី១៖ ពង្សាវតារក្សត្រទី១ ៨,២២-២៣.២៧-៣០**

ព្រះអង្គរក្សាសម្ពន្ធមេត្រី។ ១ពង្ស ៨,២

**ដំណឹងល្អ៖ ម៉ាកុស ៧,១-១៣**

អ្នករាល់គ្នាជាមនុស្សមានពុត។ មក ៧,៦

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ យើងសុំព្រះជាម្ចាស់ប្រទានព្រះពរដល់មន្ទីរពេទ្យថ្មី ជាកន្លែងមួយដើម្បីទទួលស្វាគមន៍អ្នកជំងឺ។ តាមពិត ពីប៉ុន្មានថ្ងៃយើងបានចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូ ដែលធ្វើដំណើរប្រកាសដំណឹងល្អ។ យើងបានឃើញ ព្រះយេស៊ូបានព្យាបាលណែនាំឱ្យអ្នកជំងឺយ៉ាងច្រើនបានជាសះស្បើយ។ ម្សិលមិញ យើងបានឃើញព្រះយេស៊ូទៅកន្លែងណាមួយ មហាជនក៏ទៅហ្នឹងជាមួយអ្នកជំងឺគ្រប់ប្រភេទ។ គេគ្រាន់តែពាល់តែអាវរបស់ព្រះយេស៊ូ គេដឹងថាពិតមែនគេជាសះស្បើយ ព្រះយេស៊ូយាងមកដើម្បីព្យាបាលមនុស្ស។ ព្រះយេស៊ូមានព្រះបន្ទូលថា “**មនុស្សដែលអត់មានជំងឺមិនត្រូវការគ្រូពេទ្យទេ ប៉ុន្តែខ្ញុំមកសម្រាប់មនុស្សដែលមានជំងឺ ខ្ញុំមកដើម្បីព្យាបាលគេឱ្យគេទៅជាមនុស្សថ្មី**”។

មនុស្សថ្មីនៅក្នុងពីរវិស័យ គឺទីមួយ សុខភាព រូបកាយរបស់យើង និងទីពីរ ផ្លូវវិញ្ញាណ ដើម្បីព្យាបាលយើង។ យើងដឹងថា យើងមិនអាចព្យាបាលតែរូបកាយទេ យើងត្រូវការមើលមនុស្សដ៏ពេញលក្ខណៈ ទាំងព្រលឹង ទាំងវិញ្ញាណ ទាំងចិត្ត ទាំងកម្លាំង ទាំងប្រវត្តិសាស្ត្រ ទាំងសុខភាព ទាំងអ្វីដែលមានទំនាក់ទំនងនៅក្នុងសង្គម ដើម្បីយល់អំពីអ្នកជំងឺ និងដើម្បីណែនាំឱ្យអ្នកជំងឺបានជាសះស្បើយ។ ខ្ញុំសង្ឃឹមថា គ្លីនិកនេះនឹងទៅជាកន្លែងមួយដែលមិនមែនព្យាបាលតែរូបកាយ

ប៉ុន្តែយល់យ៉ាងច្បាស់លាស់អំពីអ្នកជំងឺម្នាក់ៗ អំពីសេចក្តីត្រូវការរបស់គាត់ អំពីបញ្ហារបស់គាត់ ដើម្បីឱ្យគាត់បានទទួលការព្យាបាលជាសះស្បើយ នៅក្នុងសេចក្តីសុខសាជាថ្មី ។

បងប្អូនជាទីស្រឡាញ់ នៅក្នុងឆ្នាំ២០២១-២០២៣ ជាពេលវេលាមួយដើម្បីនឹកឃើញដល់សន្និបាតព្រះសហគមន៍កាតូលិក ដែលសម្តេចប៉ាបបានអញ្ជើញឱ្យយើងចូលរួមទាំងអស់គ្នា ក្រោមប្រធានបទ "**ដើររួមជាមួយគ្នា**"។ ដើររួមជាមួយគ្នា ទីមួយប្រកាសដំណឹងល្អ ទីពីរទៅជាផ្លូងតែមួយ និងទីបីចូលរួមយ៉ាងសកម្ម។ នេះជាគោលដៅរបស់យើងទាំងអស់ យើងជាបូជាចារ្យ យើងជាបងប្រុសបងស្រី យើងជាគ្រីស្តបរិស័ទ យើងធ្វើដំណើរជាមួយគ្នានៅក្នុងព្រះសហគមន៍។ ជាពិសេស ព្រះសហគមន៍ភូមិភាគភ្នំពេញ ដើម្បីឱ្យយើងរួមគ្នាយើងពិចារណា **តើយើងប្រកាសដំណឹងល្អរួមជាមួយគ្នាយ៉ាងដូចម្តេច?** តាមរយៈការសិក្សា តាមរយៈវិស័យសុខភាព តាមរយៈការអភិវឌ្ឍន៍ជនបទ តាមរយៈវិស័យសង្គមកិច្ច។ ជាពេលវេលាមួយដែរ ដែលយើងអាចប្រកាសដំណឹងល្អ យើងមិនធ្វើទូទៅ ប៉ុន្តែយើងធ្វើដោយនាមព្រះយេស៊ូដែលបានអញ្ជើញយើង ចាត់យើងឱ្យទៅប្រកាសដំណឹងល្អ។ ហេតុនេះហើយ កន្លែងនេះជាកន្លែងមួយដើម្បីប្រកាសដំណឹងល្អ ដោយនាមជំនឿរបស់យើងដែលជាគ្រីស្តបរិស័ទ។ កន្លែងនីមួយៗដែលយើងមាននៅក្នុងភូមិភាគភ្នំពេញ ទោះបីយើងជួយសង្គមក៏ដោយ ក៏ជាឱកាសមួយដើម្បីគិតសាជាថ្មី តាមរយៈកម្មវិធីការសិក្សារបស់ខ្ញុំ តាមរយៈកម្មវិធីអភិវឌ្ឍន៍ជនបទ តាមរយៈកម្មវិធីសុខភាព **តើខ្ញុំជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច?** ខ្ញុំណែនាំឱ្យអ្នកតូចតាច ជាពិសេសអ្នកដែលគ្មានសេចក្តីសង្ឃឹម ឬខ្វះទីពឹងអាចរកឃើញផ្លូវថ្មីនៅក្នុងជីវិតរបស់គាត់ និងទទួលពន្លឺថ្មី ដើម្បីធ្វើដំណើរទៅមុខ។

ក្នុងរយៈពេលបីឆ្នាំនេះ យើងបាននិយាយអំពីផ្លូងតែមួយ ខ្ញុំគិតថានេះជាពេលវេលាមួយដើម្បីគិតសាជាថ្មីដែរ។ ជាមូលហេតុដែលយើងមកនៅប្រទេសកម្ពុជា ក្រុម KMS ក្តី MEPក្តី យ៉េអូម៉ាល់ក្តី ក្រុមសាសនទូតនីមួយៗ ដើម្បីកសាងព្រះសហគមន៍នៅលើទឹកដីប្រទេសកម្ពុជាសព្វថ្ងៃ។ ភូមិភាគយើងប្លែក ដោយសារយើងមានសានសទូតជិត២០០នាក់ មកពីជាង២០ប្រទេស យើងមានអ្នកដែលជាកូនចៅយើង ធ្វើជាបងស្រីឬជាបូជាចារ្យតិចណាស់។ យើងមានតិច ដែលជាបូជាចារ្យដែលជាបងស្រី មកពីប្រទេសយើង។ ហេតុនេះហើយ តួនាទីរបស់យើងគឺធ្វើដូចម្តេចដើម្បីឱ្យគ្រីស្តបរិស័ទខ្មែរយើង អាចយល់ថាព្រះសហគមន៍ខ្មែរជាព្រះសហគមន៍របស់គេ ជាផ្ទះរបស់គេ។ ដូច្នេះ នេះជាគោលដៅរបស់យើងដោយសហការយ៉ាងជិតស្និទ្ធជាមួយលោកអភិបាល ធ្វើដំណើរជាមួយលោកអភិបាលជាផ្លូងតែមួយ។ មានន័យថា យើងទាំងអស់យើងជាបព្វជិតបព្វជិតា ជា

ក្រុមសាសនទូតទាំងអស់ យើងជាគ្រីស្តបរិស័ទ យើងធ្វើដំណើរជាមួយគ្នាដោយចែករំលែកបទពិសោធន៍រួមជាមួយគ្នា យើងមានកន្លែងដើម្បីចែករំលែក។

សព្វថ្ងៃ យើងមានបព្វជិតបព្វជីតាមួយចំនួនដែលចូលនៅប្រទេសកម្ពុជា ជាលក្ខណៈអង្គការ ដូចជា ដុនបូស្កូ MC DC និង KMS តាមរយៈកូមីស្យូ ជាដើម។ ដូច្នេះ យើងជាបព្វជិតបព្វជីតាដែលចូលយ៉ាងជិតស្និទ្ធនៅក្នុងសង្គម តាមរយៈសកម្មភាពរបស់យើង។ ប៉ុន្តែ យើងមានកន្លែងមួយនៅក្នុងភូមិភាគភ្នំពេញ ដើម្បីជួបជុំគ្នាដែរ យើងមានសម្ព័ន្ធកាតូលិកដើម្បីអភិវឌ្ឍន៍និងមេត្តាករុណា ដែលយើងប្រជុំមួយឆ្នាំ៤ដង។ ទោះបីមានកូវីដ-១៩ ឬអត់កូវីដ-១៩ យើងមានប្រជុំមួយឆ្នាំ៤ដង ដើម្បីជួបជុំគ្នាជាមួយបព្វជិតបព្វជីតា ដែលធ្វើការតាមវិស័យនីមួយៗ ជាមួយការិយាល័យនៅក្នុងភូមិភាគភ្នំពេញ ជាមួយអង្គការការីតាស ដែលជាអង្គការកាតូលិកសំខាន់ណាស់នៅក្នុងគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា។ សព្វថ្ងៃ យើងមានទំនាក់ទំនងនិងមានអនុស្សរណៈនៃការយោគយល់ (MOU) ជាមួយក្រសួងចំនួន៧។ ណែនាំឱ្យយើងជាគ្រួសារតែមួយ ដើម្បីចែកបទពិសោធន៍ ចែករំលែក និងខិតខំធ្វើដំណើរជាមួយគ្នានៅក្នុងការចូលរួម។ យើងមិនមែនជាគ្រួសារមួយនៅដោយឡែកពីគ្នា រៀងៗខ្លួនយើងធ្វើសកម្មភាពរបស់យើង យើងជាគ្រួសារមួយនៅក្នុងព្រះសហគមន៍កាតូលិក យើងជាអ្នកស្ម័គ្រចិត្តនៅក្នុងព្រះសហគមន៍កាតូលិក។

ហេតុនេះហើយ វត្តមានរបស់ខ្ញុំថ្ងៃនេះសំខាន់ណាស់ ខ្ញុំសង្ឃឹមថាវត្តមានរបស់ខ្ញុំថ្ងៃនេះ មិនមែនតែមកឱ្យព្រះពរ។ វត្តមានរបស់ខ្ញុំ គឺដើម្បីយល់ថាយើងធ្វើការជាមួយគ្នា យើងសហការជាមួយគ្នានៅក្នុងភូមិភាគភ្នំពេញយើងមានការិយាល័យសុខភាព សំខាន់យើងត្រូវធ្វើដូចម្តេចដើម្បីធ្វើដំណើររួមជាមួយគ្នា នៅក្នុងវិស័យសុខភាព រួមជាមួយភូមិភាគភ្នំពេញ។ ទោះបី យើងដឹងថាកន្លែងនេះមានទីតាំងដោយឡែកសព្វថ្ងៃ តែយើងដឹងថានៅថ្ងៃអនាគតវានឹងនៅកណ្តាលទីក្រុងដូចដុនបូស្កូសំរោងអណ្តែងពីដើម។ ប៉ុន្តែ អ្វីដែលសំខាន់គឺមិនមែនឆ្ងាយពីគេដោយសារទីតាំង កុំឱ្យឆ្ងាយពីគេដោយសារយើងខ្វះទំនាក់ទំនង រួមជាមួយភូមិភាគភ្នំពេញ និងរួមជាមួយការិយាល័យសុខភាពរបស់ព្រះសហគមន៍យើង។ ដូច្នេះ ខ្ញុំសង្ឃឹមថ្ងៃនេះវត្តមានរបស់ខ្ញុំ គឺណែនាំឱ្យយើងយល់ថា យើងធ្វើការតាមវិស័យសុខភាពយ៉ាងច្រើន ការីតាសនិងព្រះសហគមន៍ភូមិភាគភ្នំពេញ ដែលមានគម្រោងការរៀបចំមន្ទីរពេទ្យមួយដែរ។ សព្វថ្ងៃ យើងមានសន្តលូកា សន្តីអេលីសាប៉ែត ជាកន្លែងតែមួយនៅព្រះសហគមន៍បឹងទំពន់ យើងមានសន្តបីន័រសម្រាប់គ្រូចៀក នៅក្នុងអគារកូរ៉េភ្នំពេញថ្មី។

ដូច្នេះ យើងដឹងថាវិស័យសុខភាពអាចទៅមុខ លុះត្រាតែយើងធ្វើការជាមួយគ្នា សហការជាមួយគ្នា នេះជាអ្វីដែលសំខាន់។ ថ្ងៃនេះ ខ្ញុំសង្ឃឹមថាព្រះជាម្ចាស់ប្រទានព្រះពរដល់យើងទាំងអស់គ្នា ដើម្បីបើកទំព័រថ្មីមួយនៅក្នុងការសហការ នៅក្នុងការយល់ដឹងអំពីតួនាទីរបស់យើង។ ជាសាសនទូត ជាបូជាចារ្យ ជាបងស្រី ដើម្បីប្រកាសដំណឹងល្អអំពីព្រះរាជរបស់ព្រះជាម្ចាស់ តាមវិស័យនីមួយៗនៅក្នុងសង្គម។ ប៉ុន្តែ ណែនាំឱ្យពន្លឺរបស់ព្រះយេស៊ូអាចបំភ្លឺដល់បងប្អូនយ៉ាងច្រើន និងទទួលជីវិតថ្មីដើម្បីទៅមុខ ដើម្បីទៅជាពលរដ្ឋដែលពោរពេញដោយសុខភាពល្អ ពោរពេញដោយសេចក្តីសង្ឃឹម ពោរពេញដោយកម្លាំងកាយកម្លាំងចិត្ត ដើម្បីកសាងគ្រួសារ ដើម្បីកសាងសង្គមរបស់យើង និងដើម្បីកសាងព្រះសហគមន៍របស់យើង។

យើងអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឱ្យយើងជួបជុំគ្នានៅទីនេះ ណែនាំឱ្យយើងមានកម្លាំងថ្មី ដើម្បីធ្វើដំណើររួមជាមួយគ្នានៅក្នុងគ្រួសារតែមួយ ដែលជាគ្រួសារព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ដើម្បីឱ្យយើងរួមគ្នាណែនាំឱ្យព្រះរាជរបស់ព្រះជាម្ចាស់ កើតឡើងយ៉ាងជាក់ស្តែងលើទឹកដីរបស់យើង ទឹកដីនៃប្រទេសកម្ពុជា។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ<br>
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា<br>
ភូមិភាគភ្នំពេញ

https://youtu.be/3rFFlGVZETQ